AUSTRALIAN WATER ASSOCIATION | Water Research AUSTRALIA | Water Futures

# កិច្ចសហការស្តីពីការឃ្លាំមើលស្ថានភាពមេរោគកូរ៉ូណា នៅក្នុងបរិស្ថានទឹកស្អាត និងទឹកកខ្វក់

## ការពិពណ៌នាគម្រោង

គម្រោងនេះមានគោលបំណងផ្ទេរនវានុវត្តន៍របស់ប្រទេសអូស្ត្រាលី ក្នុងការឃ្លាំមើលស្ថានភាពនៃមេរោគកូរ៉ូណា ដើម្បីគាំទ្រដល់រដ្ឋាភិបាលនៃប្រទេសចំនួន ៥ ក្នុងអនុតំបន់ទន្លេមេគង្គ (រួមមានប្រទេសវៀតណាម ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសភូមា និងប្រទេសថៃ)ក្នុងការត្រៀម ការឆ្លើយតប និងចាកផុតពីការរាតត្បាតជំងឺកូវីដ -១៩ ។

ការផ្ទេរនវានុវត្តន៍នេះនឹងគាំទ្រដល់កិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលប្រទេសនីមួយៗក្នុងការត្រួតពិនិត្យការរាតត្បាត មេរោគកូរ៉ូណា នៅក្នុងទឹក (ទឹកកខ្វក់ និងទឹកភ្លៀង) ដើម្បីជូនដំណឹងពីយុទ្ធសាស្ត្រត្រួតពិនិត្យរបស់រដ្ឋាភិបាលលើជំងឺកូវីដ-១៩ ព្រមទាំងបន្ថែមនូវប្រអប់ឧបករណ៍ផែនការភាពជន់ក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩។

តាមរយៈការបង្កើតប្រព័ន្ធប្រកាសជូនដំណឹងជាមុនពីការរកឃើញការរីករាលដាលនៃជំងឺកូវីដ-១៩ នៅប្រទេស នីមួយៗ។ គម្រោងនេះនឹងគាំទ្ររយៈពេលវែងដល់ការពង្រឹងសន្តិសុខសុខភាព ប្រព័ន្ធ ស្ថេរភាព ភាពរួមគ្នាក្នុងសង្គម និងការស្តារសេដ្ឋកិច្ចនៅទូទាំងអនុតំបន់ទន្លេមេគង្គ។

## សាវតា និងបរិបទ

ការស្រាវជ្រាវទឹកប្រទេសអូស្ត្រាលី (WaterRA) កំពុងដឹកនាំកិច្ចសហប្រតិបត្តិការស្រាវជ្រាវទូទាំងប្រទេសអូស្ត្រាលី ដើម្បីដាក់បញ្ចូលការធ្វើតេស្តទឹកកខ្វក់ជាមួយ ទិន្នន័យសុខាភិបាលសម្រាប់មេរោគកូរូណា។ ការធ្វើតេស្តទៀងទាត់កំពុងធ្វើនៅ "Nodes" ដែលបង្កើតឡើងនៅទូទាំងប្រទេសអូស្ត្រាលី ក្នុងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធដូចជា ភ្នាក់ងារសុខាភិបាល និងភ្នាក់ងារផ្គត់ផ្គង់ទឹក។ គម្រោងនេះនឹងបង្កើតទីតាំងក្នុងអនុតំបន់ទន្លេមេគង្គ ក្នុងកិច្ចសហប្រតិបត្តិការដើម្បីឃ្លាំមើលស្ថានភាពមេរោគកូរូណានៅក្នុងទឹកកខ្វក់សម្រាប់គម្រោង ColoSSos ។

បទពិសោធន៍របស់ប្រទេសអូស្ត្រាលី និងអន្តរជាតិ បង្ហាញថាវិធីសាស្ត្រទាំងនេះអាចផ្តល់នូវមធ្យោបាយដ៏ឆាប់រហ័សក្នុងការរកឃើញវត្តមានមេរោគកូរ៉ូណា ដែលកំពុងបានហូរចូលទៅក្នុងបណ្តាញលូទឹកកខ្វក់ និងជួយកំណត់ការឆ្លង មុនពេលករណីនេះត្រូវរាយការណ៍ទៅគ្លីនិច។ ដូច្នេះហើយវិធីសាស្ត្រនេះផ្តល់នូវឧបករណ៍ដ៏មានប្រយោជន៍ សម្រាប់ការប្រកាសជូនដំណឹងជាមុននៃការកើតឡើងជាថ្មីនៃរលកទីពីរ។ លើសពីនេះទៀតឧបករណ៍នេះអាចប្រើសម្រាប់ការតាមដានប្រសិទ្ធិភាពនៃវិធានការត្រួតពិនិត្យជំងឺកូវីដ-១៩ និងការតាមដានការធ្លាក់ចុះ និងការបាត់មេរោគនេះពីសហគមន៍។ ដោយរួមជាមួយកស្តុតាងដែលបានមកពីការធ្វើតេស្តនៅគ្លីនិក និងការត្រួតពិនិត្យផ្សេងៗការធ្វើតេស្តស្ថានភាពនេះផ្តល់នូវឧបករណ៍មួយដែលមានសារៈប្រយោជន៍បន្ថែម ដើម្បីជូនដំណឹងដល់អាជ្ញាធរសុខាភិបាល និងគាំទ្រយុទ្ធសាស្ត្រត្រួតពិនិត្យការរាតត្បាតនៃជំងឺកូវីដ-១៩។

## គោលបំណង

គម្រោងនេះមានគោលបំណងផ្ទេរនវានុវត្តន៍របស់ប្រទេសអូស្ត្រាលី ដើម្បីត្រួតពិនិត្យមេរោគកូរ៉ូណាក្នុងបណ្តាញលូ ក្នុងទឹកកខ្វក់ និងទឹកភ្លៀង ទៅឱ្យប្រទេសវៀតណាម ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសភូមា និងប្រទេសថៃ ដើម្បីជូនដំណឹងពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើជំងឺកូវីដ-១៩ តាមរយៈ ៖

- ការចែករំលែកការអនុវត្តល្អលើការយកសំណាក និងការធ្វើតេស្ត មេរោគកូរ៉ូណា ក្នុងទឹកលូ ទឹកកខ្វក់ និងទឹកភ្លៀង
- បង្កើតឧបករណ៍ដាក់បញ្ចូលទិន្នន័យពីគម្រោងនេះ ជាមួយទិន្នន័យពីការធ្វើតេស្តជាបុគ្គលដើម្បីជួយដល់ រដ្ឋាភិបាលប្រទេសវៀតណាម ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសភូមា និងប្រទេសថៃ រកឃើញការរីករាលដាលនៃជំងឺកូវីដ-១៩ និងប្រសិទ្ធិភាពនៃការដាក់បម្រាម
- គាំទ្រទីប្រជុំជន ទីជនបទ សហគមន៍ដាច់ស្រយាល និងសហគមន៍ងាយរងគ្រោះ ដោយសារហេដ្ឋារចនាសម្ព័ន្ធផ្នែកសុខាភិបាលរបស់សហគមន៍នោះនៅមានកម្រិត ដែលជួយឱ្យការវិនិយោគបានឆ្លើយតបទៅក្រុមគោលដៅនោះ
- គាំទ្រដល់ការឃ្លាំមើលស្ថានភាពជាប្រចាំសម្រាប់បង្កាភ្នាក់ងារបង្កជំងឺ និងប្រកាសជូនដំណឹងជាមុនក្នុងការជួយឱ្យរដ្ឋាភិបាលអនុវត្តសកម្មភាពឆ្លើយតបបានឆាប់ និងមានប្រសិទ្ធិភាព។
- សម្របសម្រួលមជ្ឈមណ្ឌលចំណេះដឹងមេគង្គសម្រាប់អ្នកអនុវត្តដើម្បីទទួលបានចំណេះដឹង ព្រមទាំងចែករំលែកបទពិសោធន៍ក្នុងការអនុវត្តវិធីសាស្ត្រទាំងនោះ។

Supported by:

Australian Government

THE AUSTRALIAN WATER PARTNERSHIP

## វិធីសាស្ត្រ និងរយៈពេល

គម្រោងនេះនឹងត្រូវបែងចែកជាពីរដំណាក់កាល។ សកម្មភាពដំណាក់កាលទី១ រួមមាន៖

**១. សប្តាហ៍ទី ១-៤៖ បង្កើតភាពជាដៃគូ និងការរៀបចំអភិបាលកិច្ច៖**

ក. អង្គភាពគ្រប់គ្រងគម្រោងពិនិត្យមើលការអនុវត្តគម្រោងប្រចាំថ្ងៃ

ខ. ការបង្កើតគណៈកម្មាធិការសម្របសម្រួលគម្រោង (PCC) សម្រាប់ប្រទេសនីមួយៗរួមមានក្រសួងសុខាភិបាល ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងធនធានទឹក ភ្នាក់ងារស្រាវជ្រាវ និងអភិវឌ្ឍន៍ និងក្រុមហ៊ុនផ្គត់ផ្គង់ទឹក។

គណៈកម្មាធិការសម្របសម្រួលគម្រោង (PCCs) នឹងត្រូវបានកំណត់ដោយគណៈកម្មាធិការដឹកនាំការឃ្លាំមើលជំងឺកូវីដ-១៩ ដែលមានស្រាប់ហើយបានបង្កើតរួចហើយក្នុងប្រទេសនីមួយៗ និងសម្របសម្រួលសកម្មភាពប្រទេសនោះ ដើម្បីធានាថាវិធីសាស្ត្រដែលបង្កើតឡើងបានដាក់បញ្ចូលទូលំទូលាយនូវវិធានការឃ្លាំមើល និងឆ្លើយតប របស់ប្រទេសនីមួយៗ។ សមាគមទឹកអូស្ត្រាលី(AWA) និងសមាគមជាដៃគូរបស់ពួកគេ នឹងផ្តល់ជាលេខាធិការដ្ឋានសម្រាប់គណៈកម្មាធិការនេះ ។

គ. ការបង្កើតភាពដៃគូមួយនិងមួយ និងការពិគ្រោះយោបល់រវាង៖

i. ប្រទេសអូស្ត្រាលីជាមួយនឹងមន្ទីរពិសោធន៍ជាដៃគូនៅបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ

ii. ក្រុមហ៊ុនផ្គត់ផ្គង់ទឹកអូស្ត្រាលី និងក្រុមហ៊ុនផ្គត់ផ្គង់ទឹកនៅបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ

iii. ភ្នាក់ងារសុខាភិបាលប្រទេសអូស្ត្រាលី និងភ្នាក់ងារសុខាភិបាលនៅបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ

ភាពជាដៃគូនេះនឹងត្រូវសម្របសម្រួលដោយសមាគមទឹកអូស្ត្រាលី(AWA) និង ការស្រាវជ្រាវទឹកប្រទេសអូស្ត្រាលី (WaterRA) ហើយរាយការណ៍ទៅគណៈកម្មាធិការសម្របសម្រួលគម្រោង(PCCs )។

ឃ. ការបង្កើតមជ្ឈមណ្ឌលចំណេះដឹងមេគង្គ (MKH) សម្រាប់ប្រមូលវិធីសាស្ត្រ ចែករំលែកចំណេះដឹង និងឧបករណ៍ដែលបានបង្កើតឡើងហើយបានអនុវត្តនៅប្រទេសនីមួយៗ និងគាំទ្រការប្រាស្រ័យទាក់ទងនៃការសម្រេចលទ្ធផលភ្លាមៗ និងលទ្ធផលរយៈពេលវែងបានកាន់តែទូលំទូលាយ។ សមាជិកនៃ MKH នឹងត្រូវបានតែងតាំងដោយ PCC ប្រចាំប្រទេសនីមួយៗក្នុងអំឡុងកិច្ចប្រជុំលើកដំបូងរបស់ពួកគេ។

**២- សប្តាហ៍ ៥-១៨៖ រៀបចំស្តង់ដារ កម្មវិធីបណ្តុះបណ្តាល និងការសាកល្បងគម្រោង៖**

ក. រៀបចំកម្មវិធីឱ្យមានការឃ្លាំមើលជាប្រចាំ និងរៀបចំគំរូស្តង់ដារសម្រាប់ប្រទេសនីមួយៗដោយពិគ្រោះយោបល់ជាមួយ PCCs

ខ. ធ្វើឱ្យប្រសើរឡើងនូវការវិភាគមន្ទីរពិសោធន៍ និងការសាកល្បងស្តង់ដារនោះ ដើម្បីឱ្យសមស្របទៅនឹងវិធីសាស្ត្ររបស់ប្រទេសនីមួយៗ

គ.បង្កើតដំណើរការសម្រាប់ការ វាយតម្លៃនិងដាក់បញ្ចូលទិន្នន័យនោះទៅក្នុងវិធីសាស្ត្រតាមដានរបស់រដ្ឋាភិបាលឱ្យបានកាន់តែទូលំទូលាយ។

ឃ. ការប្រាស្រ័យទាក់ទងជាមួយរដ្ឋាភិបាលរួមមានក្រុមសុខាភិបាល និងក្រុមត្រួតពិនិត្យជំងឺកូវីដ-១៩

**៣- សប្តាហ៍ទី ១៩-២២ : គ្រោងការណ៍ និងផែនទីបង្ហាញសម្រាប់ការអនុវត្តដំណាក់កាលទី ២:**

របាយការណ៍នេះនឹងដាក់ចេញនូវសកម្មភាពដំណាក់កាលទី២ រវាងអ្នកស្រាវជ្រាវ ក្រុមហ៊ុនផ្គត់ផ្គង់ទឹក មន្ទីរពិសោធន៍ និងមន្ត្រីសាធារណៈ រួមទាំងផ្តល់វគ្គបណ្តុះបណ្តាល និងកសាងសមត្ថភាពស្តីពីការឃ្លាំមើលស្ថានភាព និងការផ្ទេរឧបករណ៍ការឃ្លាំមើលស្ថានភាព ព្រមទាំងសាកល្បងកម្មវិធីទាំងនោះក្នុងតំបន់អាទិភាពដែលបានកំណត់ក្នុងភាពជាដៃគូរបស់ប្រទេសនីមួយៗក្នុងដំណាក់កាលទី ១ ។

### លទ្ធផលភ្លាមៗ

លទ្ធផលភ្លាមៗនៃសកម្មភាពដំណាក់កាលទី ១ រួមមាន៖

១. ឯកភាព និងអនុវត្តកាលវិភាគកិច្ចប្រជុំ និងអភិបាលកិច្ច ដោយដៃគូគម្រោង

២.បង្កើតស្តង់ដារជាមួយដៃគូគម្រោងទាំងអស់ដោយកំណត់តួនាទី និងការទទួលខុសត្រូវដើម្បីអនុវត្តគម្រោង

៣.វីដេអូបណ្តុះបណ្តាល និងវគ្គបណ្តុះបណ្តាលស្តីពីការឃ្លាំមើលស្ថានភាពមេរោគកូរ៉ូណា

៤.ការបកប្រែស្តង់ដារដែលបានរៀបចំរួចជាភាសាវៀតណាម ភាសាខ្មែរ ភាសាឡាវ ភាសាភូមា និងភាសាថៃ

៥.កម្មវិធីវិភាគទិន្នន័យ និង តារាងឧបករណ៍

៦.ការបោះពុម្ពផ្សាយដូចជាឯកសារព័ត៌មាន នីតិវិធី អត្ថបទឧស្សាហកម្ម និងរបាយការណ៍វិទ្យាសាស្ត្រ

៧.ការស្វែងមតិពីមេរោគកូរ៉ូណានៅក្នុងទឹកកង្វក់

អត្ថប្រយោជន៍នៃលទ្ធផលភ្លាមៗដែលកើតឡើងមានពីរ៖

១. ការឃ្លាំមើលស្ថានភាពនៃមេរោគកូរ៉ូណា ព្រមទាំងផ្តល់នូវផ្តល់នូវឧបករណ៍ដែលអាចទុកចិត្តបានក្នុងការរកឃើញពេលវេលាគ្រោះថ្នាក់ នឹងជួយរដ្ឋាភិបាលឱ្យ៖

- កំណត់ពីការរីករាលដាលនៃការឆ្លងមេរោគកូរ៉ូណា និងជំងឺកូវីដ-១៩
- ប៉ាន់ប្រមាណពីឥទ្ធិពលនៃយុទ្ធសាស្ត្រត្រួតពិនិត្យ
- ផ្តល់ការប្រកាសដំណឹងជាមុនអំពីការកើនឡើងនៃការរីករាលដាលនេះ
- តាមដានការថយចុះនៃការរីករាលដាលនេះទៅតាមពេលវេលា
- កំណត់តំបន់ដែលងាយផ្ទុះឡើងនៃជំងឺនេះ

២. ការយល់ដឹងអំពីការកើតឡើងនៃជំងឺនេះនៅទីប្រជុំជន ទីជនបទ និងសហគមន៍ដាច់ស្រយាល នឹងជួយដល់ រដ្ឋាភិបាលនីមួយៗខិតខំប្រឹងប្រែងឆ្លើយតប និងវិយោគទៅនឹងក្រុមគោលដៅបានល្អ។

ដូច្នេះស្តង់ដារ និងចំណេះដឹងដែលបានចែករំលែក នឹងត្រូវរៀបចំឱ្យបានល្អ និងបកប្រែ ដើម្បីជួយគាំទ្ររដ្ឋាភិបាលប្រទេសវៀតណាម ប្រទេសកម្ពុជា ប្រទេសឡាវ

ប្រទេសភូមា និងប្រទេសថៃ ក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩ ។

## លទ្ធផលរយៈពេលវែង និងអ្នកទទួលផល

លទ្ធផលរយៈពេលវែង និងអ្នកទទួលផលរួមមាន៖

១.ពង្រឹងសមត្ថភាពបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គឃ្លាំមើលស្ថានភាពមេរោគក្សរ៉ូណា និងភ្នាក់ងារបង្កជំងឺដទៃទៀត

២.ប្រកាសជូនដំណឹងជាមុន ពីការរកឃើញនៃការផ្ទុះឡើងនៃជំងឺកូវីដ-១៩

៤.ការចំណាយទាបក្នុងការរកឃើញពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងតាមដានការរីករាលដាលមេរោគក្សរ៉ូណានៅក្នុងសហគមន៍

៤.កាត់បន្ថយផលប៉ះពាល់ផ្នែកសុខាភិបាល និងសេដ្ឋកិច្ចដោយសារជំងឺកូវីដ-១៩ ក្នុងតំបន់

៥.ត្រលប់ទៅរកភាពប្រក្រតីវិញបានឆាប់ និងកាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច

៦.វិធីសាស្ត្រធ្វើឱ្យប្រសើរឡើងពីការផ្តល់ដំណឹងអំពីនិន្នាការ និងការប៉ាន់ប្រមាណការរីករាលដាលនៃមេរោគក្សរ៉ូណា និងជំងឺកូវីដ-១៩នៅសហគមន៍។

## សំណួរ និងចម្លើយ

*ហេតុអ្វីត្រូវឃ្លាំមើលស្ថានភាពមេរោគក្សរ៉ូណា ?*

- ដើម្បីផ្តល់នូវការចំណាយឱ្យមានប្រសិទ្ធិភាពទៅលើការឃ្លាំមើលទៅសហគមន៍ដែលមិនមានការរាតត្បាត តាមដាននិន្នាការរបស់មេរោគក្សរ៉ូណាដែលហូរចូលទៅក្នុងសហគមន៍ និងដើម្បីប្រកាសដំណឹងជាមុនពី អត្រាកើនឡើងនៃការឆ្លងមេរោគនេះ
- ដើម្បីផ្តល់ទិន្នន័យមួយផ្នែកបន្ថែមទៀត ក្នុងការផ្តល់ព័ត៌មានពីយុទ្ធសាស្ត្រគ្រប់គ្រងជំងឺកូវីដ-១៩ដោយភ្ជាប់ជាមួយទិន្នន័យផ្សេងៗទៀត ( ដូចជាការធ្វើតេស្តគ្លីនិក )
- ដើម្បីឱ្យស្របជាមួយបទដ្ឋាន អន្តរជាតិ (វិធីសាស្ត្រនេះកំពុងប្រើប្រាស់ជាសកល )
- ដើម្បីជួយផ្តល់ជាភស្តុតាងនៃកម្រិតរបស់មេរោគក្សរ៉ូណានៅក្នុងប្រទេស ឬតំបន់ និងផ្តល់ព័ត៌មានព្រមទាំងធ្វើសេចក្តីសម្រេចក្នុងការធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយ និងតំបន់ផ្សេងៗទៀត។

*តើការឃ្លាំមើលពីស្ថានភាពមេរោគក្សរ៉ូណាបានអនុវត្តនៅកន្លែងណា ?*

- នៅទូទាំងពិភពលោកនៅក្នុងប្រទេសភាគច្រើននៃ OECD និងប្រទេសដែលមិនមែនជា OECD

*តើសំណាកត្រូវយកមកពីណា ?*

- សំណាកត្រូវយកមកពីរោងចក្រប្រព្រឹត្តកម្មទឹកកង្វក់ដែលត្រូវបង្ហូរទឹកលូចូល និងពីសំណាកបរិស្ថានដូចជាទឹកភ្លៀងដែលយកពីពីអគារ និងនៅតំបន់ឧស្សាហកម្ម

*តើមានអ្វីកើតឡើងចំពោះលទ្ធផល ?*

- លទ្ធផលត្រូវបានវាយតម្លៃជាផ្នែកមួយនៃភស្តុតាងឱ្យកាន់តែទូលំទូលាយពីការធ្វើតេស្តគ្លីនិកតាមដានទំនាក់ទំនង និងចលនាព័ត៌មាន
- លទ្ធផលជួយឱ្យការផ្តល់ព័ត៌មានការឆ្លើយតបក្នុងការប៉ាន់ប្រមាណហានិភ័យ និងណែនាំពីយុទ្ធសាស្ត្រត្រួតពិនិត្យជំងឺកូវីដ-១៩

*ហេតុអ្វីបានជាមិនចាប់ផ្តើមធ្វើការឃ្លាំមើលមេរោគក្សរ៉ូណានេះឱ្យបានឆាប់ ?*

- កិច្ចការនេះអាចធ្វើទៅបានដោយប្រើមន្ទីរពិសោធន៍ដែលមានសមត្ថភាព មានជំនាញក្នុងការធ្វើតេស្តមេរោគក្នុងទឹកកខ្វក់
- ត្រូវចំណាយពេលយូរសម្រាប់ដំណើរការរដ្ឋបាលទើបអាចដំណើរការបាន (ថវិកា និងកិច្ចសន្យា)
- បន្ទាប់ពីនោះវិធីសាស្ត្រនានាត្រូវរៀបចំជាចាំបាច់ ត្រូវការបណ្តុះបណ្តាលបុគ្គលិក ឧបករណ៍ដែលត្រូវយកមកធ្វើតេស្តត្រូវមានប្រភពច្បាស់លាស់ និង វិធីសាស្ត្រនានាត្រូវមានការបញ្ជាក់និងមានភាពត្រឹមត្រូវ
- ជាការសំខាន់ណាស់ដែលលទ្ធផលត្រូវមានគុណភាពខ្ពស់ហើយការងារដែលអនុវត្តភ្លាមៗពេកធ្វើឱ្យលទ្ធផលមិនមានភាពសុក្រឹត

*តើការងារនេះនឹងបញ្ចប់ពេលណា ?*

- កម្រិតនៃការធ្វើតេស្តនឹងធ្លាក់ចុះនៅពេលដែលភាពស៊ាំនឹងមេរោគនេះត្រូវបានគេទទួលស្គាល់ ជាសកលឧទាហរណ៍: ចាក់វ៉ាក់សាំង
- ការធ្វើតេស្តទាំងនេះប្រហែលជានឹងបន្តរយៈពេលជាច្រើនឆ្នាំទៀតទោះបីជាមានវ៉ាក់សាំងហើយក៏ដោយ ដូចដែលបានធ្វើជាមួយមេរោគផ្សេងទៀតដែរ។ យើងនៅបន្តធ្វើតេស្តជាប្រចាំលើសំណាកបរិស្ថានដើម្បីឃ្លាំមើលការលេចចេញជាថ្មី ឬការវិវត្តនៃមេរោគផ្សេងទៀត។
- យើងនៅតែធ្វើតេស្តជាប្រចាំនូវមេរោគ norovirus និង adenovirus និងមេរោគផ្សេងទៀតដើម្បីតាមដានការរាតត្បាត និងឆ្លងតាមរដូវកាល និងឃ្លាំមើលមេរោគដែលកើតឡើងថ្មីៗទៀត។

*តើអ្នកផ្តល់សេវាកម្មទឹកស្អាត ទឹកកង្វក់ និងទឹកភ្លៀង ត្រូវជាមួយនឹងការងារនេះយ៉ាងដូចម្តេច ?*

- មានតែអ្នកផ្តល់សេវាកម្មទឹកប៉ុណ្ណោះដែលដឹងអំពីបណ្តាញទឹកកខ្វក់ និងទឹកភ្លៀង និងណែនាំកន្លែងដែលត្រូវទៅយកសំណាក
- មានតែពួកគេទេដែលស្គាល់តំបន់នោះច្បាស់ និងផ្នែកណានៃសហគមន៍ដែលជាចំណុចត្រូវយកសំណាក ឬសំណាកណាដែលត្រូវជ្រើសរើសដើម្បីឱ្យត្រូវនឹងចំនួនប្រជាពលរដ្ឋបានបានច្រើនបំផុត
- ពួកគេដឹងពីប្រព័ន្ធធារាសាស្ត្រ និងលំហូរដដែលៗ ហើយជួយណែនាំពេលដែលត្រូវយកសំណាក និងថាតើមានសមាសភាពក្នុងសំណាក
- មានតែពួកគេ អ្នកយកសំណាក និងបន្ទប់ពិសោធន៍ដែលបានចុះកិច្ចសន្យាប៉ុណ្ណោះអាចយកសំណាកបែបនេះបានដោយសារតែមានហានិភ័យលើសុខភាព និងសុវត្ថិភាពក្នុងការយកសំណាកបែបនេះ

*តើគេត្រូវយកសំណាកមកតាមរបៀបណា ?*

- ការជ្រើសសំណាកប្រើស្តង់ដារដេបសំណាកមីក្រូជីវសាស្ត្រ

- ការជ្រើសសំណាកអាចត្រូវបានធ្វើឡើងដោយការប្រើម៉ាស៊ីនស្វ័យប្រវត្តិទៅគួបផ្សំនឹងសំណាក-ការផ្សំដោយប្រើដៃអាចត្រូវបានប្រើជាជាងការផ្សំដោយម៉ាស៊ីនស្វ័យប្រវត្តិអាស្រ័យលើអ្វីដែលអាចធ្វើបាន
- សំណាកត្រូវទុកក្លាសេនៅពេលដែលយកមក ដូចនឹងសំណាកមីក្រូជីវសាស្ត្រធម្មតា

*តើអ្នកដឹងទេថានៅពេលណាត្រូវយកសំណាក ?*
- ជាកាល្អបំផុតដែលត្រូវយកសំណាកក្នុងពេលដែលមានការប្រើប្រាស់ទឹកច្រើនដូចជា ការប្រើសាប៊ូងូតទឹក លាងមុខ ដុសធ្មេញ បោកគក់សម្លៀកបំពាក់ ការប្រើប្រាស់បង្គន់ និងទម្លាប់ប្រចាំថ្ងៃផ្សេងៗទៀត។ នៅពេលព្រឹកក្នុងប្រព័ន្ធលូនេះជាពេលដែលល្អបំផុតក្នុងការយកសំណាក
- សម្រាប់កម្មករប្តូរវេននៅតំបន់ឧស្សាហកម្មត្រូវតម្រូវពេលវេលាឱ្យសមរម្យសម្រាប់ពួកគេក្នុងការយកសំណាក

*តើអ្នកណាអាចធ្វើតេស្តបាន ?*
- នេះគឺជាការងារជំនាញជាន់ខ្ពស់ដែលអាចមានបញ្ហាកើតឡើងជាច្រើនសម្រាប់អ្នកចាប់ផ្តើមធ្វើការដំបូង ដូច្នេះការងារនេះគួរធ្វើឡើងដោយអ្នកជំនាញតែប៉ុណ្ណោះ
- មន្ទីរពិសោធន៍ភាគច្រើនត្រូវបានទទួលស្គាល់ដោយ ISO / IEC 17025 ដែលមានបទពិសោធន៍យូរឆ្នាំក្នុងការធ្វើតេស្តរកមេរោគក្នុងទឹកកខ្វក់ ។ ឧទាហរណ៍ ដូចជាការធ្វើតេស្តសម្រាប់រកមេរោគស្វិតដៃជើង
- ភ្នាក់ងារនៅក្រុមហ៊ុនផ្គត់ផ្គង់ទឹក មន្ទីរពិសោធន៍សុខភាព ដែលមានបទពិសោធន៍ច្រើនឆ្នាំក្នុងការធ្វើតេស្តទឹកកខ្វក់

*តើអ្វីជាចំណុចសំខាន់ដើម្បីសម្រេចជោគជ័យក្នុងការងារនេះ ?*
- ទាមទារឱ្យមានកិច្ចសហការគ្នារវាងអ្នកផ្គត់ផ្គង់សេវាទឹក និងភ្នាក់ងារសុខាភិបាល មន្ទីរពិសោធន៍ឯកជន រដ្ឋាភិបាល និងទីភ្នាក់ងារស្រាវជ្រាវ
- ប្រជាពលរដ្ឋត្រូវធ្វើការជាមួយគ្នាក្នុងការកៀរគររួបរួមដើម្បីផលប្រយោជន៍សុខភាពសាធារណៈ ដែលនេះជួយដល់សេដ្ឋកិច្ច និងជួយឱ្យការធ្វើតេស្តអាចប្រព្រឹត្តិទៅបានដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងការឃ្លាំមើលកម្រិតថ្នាក់ជាតិ

## សម្រាប់ព័ត៌មានបន្ថែមសូមស្វែងរកនៅក្នុងគេហទំព័រ/ឯកសារខាងក្រោម៖


https://www.abc.net.au/news/2020-09-05/sa-new-coronavirus-cases-in-wastewater-and-hotel-quarantine/12633414


https://www.abc.net.au/news/2020-09-09/why-victoria-is-using-sewerage-testing-to-help-detect-covid-19/12645276


https://www.abc.net.au/news/2020-09-05/covid-in-apollo-bay-victoria-wastewater/12633756



Looking To The Sewers For Early Coronavirus Warning, Sept 2020


Wastewater tests for COVID launching in bid to spot outbreaks early, newsGP, Sept 2020


twitter.com/9NewsSyd/status/1257226786791972865?s=20


www.sheppnews.com.au/news/2020/05/05/1159097/gv-water-testing-for-covid-19-in-sheppartons-sewerage


www.theage.com.au/national/victoria/scientists-to-test-sewage-for-years-to-track-covid-bug-20200502-p54p90.html


Testing sewage for traces of coronavirus, ABC News



Ballarat Courier, Ballarat, 7 May 2020


smartwatermagazine.com/news/water-research-australia/waterra-sewage-surveillance-collaboration-support-australias-covid-19



Sunday Times, Perth, 24 May

Supported by:

Australian Government

THE AUSTRALIAN WATER PARTNERSHIP